# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីសម្រេចកែសម្រួលលើកទី៤
## លើឯកសារអាជ្ញាប័ណ្ណរួមលេខ ០២០ ឯអ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២
## ជាមួយសេចក្តីសម្រេចកែសម្រួលលើកទី៣ លេខ ០៦៨ សរ.០៦.អអក
## ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
## សម្រាប់លោក ឈូ ឡៃ
## អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណលេខ០២០ឯអ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២

-យោងសេចក្តីសម្រេចកែសម្រួលលើកទី៣ លើឯកសារអាជ្ញាប័ណ្ណរបស់លោក ឈូ ឡៃ លេខ០៦៨ សរ-០៦-អអក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

-យោងពាក្យស្នើសុំពង្រីកតំបន់ចែកចាយអគ្គិសនីរបស់លោក ឈូ ឡៃ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ដល់ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៧

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី១១៥ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧

## សម្រេច

### ប្រការ១

កែសម្រួលអាជ្ញាប័ណ្ណលេខ ០២០ ឯអ ដែលបានផ្តល់ឱ្យលោក ឈូ ឡៃ ដោយអនុញ្ញាតឱ្យពង្រីកតំបន់តាមបណ្តោយផ្លូវនៅទីរួមស្រុកព្រៃកប្បាសចម្ងាយ ២៨០០ម៉ែត្រ ចាប់ពីព្រំប្រទល់តំបន់ចែកចាយអគ្គិសនីមានស្រាប់ឆ្ពោះទៅទីរួមស្រុកបាទី គឺនៅភូមិរកា និងភូមិត្រពាំងរាំង, ឃុំស្មោង ស្រុកព្រៃកប្បាស ខេត្តតាកែវ ដើម្បីអនុញ្ញាតឱ្យលោក ឈូ ឡៃ ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់បន្ថែម ដូចមានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ ។

### ប្រការ២

ឧបសម្ព័ន្ធទី១ ចាស់នៃអាជ្ញាប័ណ្ណលេខ ០២០ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធ ទី១ កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។

**ប្រការ៣**

សេចក្ដីសម្រេចនេះនិងឧបសម្ព័ន្ធកែសម្រួលថ្មីនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃ ឯកសារអាជ្ញាប័ណ្ណលេខ ០២០ ឯអ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០២០ឯអ និងខ្លឹមសារ ដែលបានកែសម្រួលរួចហើយ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្ដីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើរសេចក្ដីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែង ដែលឯកសារអាជ្ញាប័ណ្ណលេខ ០២០ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ០២០ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្រប តាមសេចក្ដីសម្រេចនេះ ។

ភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

**ឧបសម្ព័ន្ធទី១**

**តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី**

**ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា**

**លើកទី១៤ នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧**

១- តំបន់អនុញ្ញាតឱ្យលោក ឈូ ឡៃ ធ្វើសេវាកម្មចែកចាយនិងផ្គត់ផ្គង់អគ្គិសនី គឺ នៅឃុំស្នោ និងឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ។

២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ "ផែនទីកំណត់ព្រំ ប្រទល់លេខ 020 LD-map- Chhou Lay- Revised-4- 2007 " ដែលភ្ជាប់មកជាមួយ ។

៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើលោក ឈូ ឡៃ មានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះលោក ឈូ ឡៃ ត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញសេចក្តីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិការ ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។